**ទី១៖ សេវាសាធារណៈ**

តើអ្នកកំណត់សេវាសាធារណៈយ៉ាងដូចម្តេច? (How would you define public service?)

សេវាសាធារណៈ ឬសេវាកម្មសាធារណៈ[1] ដែលភាសាអង់គ្លេសហៅថា "Public Service or Public Utilities" ឬ ជាភាសាបារាំងហៅថា "Le Service Public" ត្រូវបានប្រើប្រាស់ និងអនុវត្តយ៉ាងទូលំទូលាយនៅក្នុងប្រទេសអភិវឌ្ឍន៍ តាំងពីសតវត្សរ៍ទី១៩ មកម្លេះ ។ សេវាសាធារណៈ មានច្រើនប្រភេទ និងត្រូវបានកំណត់និយមន័យផ្សេងៗពីគ្នាទៅតាមប្រទេសនីមួយៗ ស្របជាមួយនឹងការប្រែប្រួលនៃពេលវេលា និងទីកន្លែងរបស់វា។ ការវិវត្តនៃប្រវត្តិសាស្ត្ររបស់ប្រទេសនីមួយៗ គឺផ្សារភ្ជាប់ទៅនឹងសកម្មភាពជាច្រើននៃការបម្រើប្រយោជន៍ទូទៅរបស់សង្គម ដូចជា សកម្មភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ សកម្មភាពទាំងនេះភាគច្រើនត្រូវបានបំពេញដោយរដ្ឋផ្ទាល់តែម្តង ក្រោយមកទើបគេឃើញមានស្ថាប័នមិនមែនរដ្ឋត្រូវបានអនុញ្ញាតឲ្យបំពេញសេវាទាំងនោះដែរ ប៉ុន្តែស្ថិតនៅក្រោមការត្រួតពិនិត្យរបស់រដ្ឋ។ ទោះជាយ៉ាងណាក្តីគេនៅមានការពិបាកក្នុងការកំណត់ឲ្យបានច្បាស់លាស់ ថាសេវាប្រភេទណាខ្លះជាសេវាសាធារណៈ ព្រោះថាសេវាសាធារណៈ ប្រែប្រួលទៅតាមតម្រូវការ និងការវិវត្តរបស់សង្គម ហើយរដ្ឋត្រូវមានកាតព្វកិច្ចក្នុងការផ្តល់ជូនប្រជាពលរដ្ឋរបស់ខ្លួននូវសេវាទាំងនោះជាចាំបាច់។

ដូចនេះ ដើម្បីងាយស្រួលក្នុងការកំណត់អំពីសេវាសាធារណៈឲ្យបានច្បាស់លាស់ ចំណុចធំៗចំនួន២នឹងត្រូវលើកយកមកសិក្សា គឺ (១) សញ្ញាណនៃសេវាសាធារណៈ ដែលរួមមាន៖ និយមន័យ ចរិតលក្ខណៈ និងចំណាត់ថ្នាក់នៃសេវាសាធារណៈ និង(២) របបគតិយុត្តក្នុងការបង្កើត និងការផ្តល់សេវាសាធារណៈ។

## ១. សញ្ញាណសេវាសាធារណៈ

### ក. និយមន័យនៃសេវាសាធារណៈ

សេវាសាធារណៈ ត្រូវបានកំណត់និយមន័យជាច្រើនទៅតាមប្រភពផ្សេងៗគ្នា។ ខាងក្រោមនេះ ជាការស្រង់នូវប្រភព៣ ដែលបង្ហាញពីនិយមន័យនៃសេវាសាធារណៈ ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា។

**ប្រភពទី១៖**

តាមគេហទំព័រ Wikipedia បានកំណត់និយមន័យសេវាសាធារណៈថា ជាសេវាដែលត្រូវផ្តល់ជូនប្រជាពលរដ្ឋដោយរដ្ឋផ្ទាល់[2] ឬតាមរយៈការផ្តល់ហិរញ្ញប្បទានឲ្យវិស័យឯកជនជាអ្នកផ្តល់ជំនួស។ មានន័យថាសេវាចាំបាច់មួយចំនួនគួរតែត្រូវបានបង្កើតឡើង និងផ្តល់ឲ្យប្រជាពលរដ្ឋអាចប្រើប្រាស់បានគ្រប់ៗគ្នា ដោយមិនគិតពីកម្រិតចំណូល ឬស្ថានភាពគ្រួសាររបស់ពួកគាត់។ សេវាសាធារណៈក្នុងន័យនេះ រួមមាន៖ ការអប់រំ ការការពារបរិស្ថាន អគ្គីសនី សុខាភិបាល ការអនុវត្តច្បាប់ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ សេវាដឹកជញ្ជូន ការផ្គត់ផ្គង់ទឹក ប្រៃសនីយ៍ និងទូរគមនាគមន៍ ការគ្រប់គ្រងសំរាម សេវាការពារជាតិ ។ល។

---

[1] Chan-Sangvar Theng, *Le Service Public au Cambodge*, 2007, p. 193៖ នីតិនិពន្ធ បានប្រើពាក្យ "សេវាសាធារណៈ" ។ ដោយឡែក អនុក្រឹត្យស្តីពីការអនុវត្តច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ បានប្រើពាក្យ "សេវាកម្មសាធារណៈ"។ អ្នកច្បាប់ និងលទ្ធិគតិយុត្តយល់ឃើញថា ពាក្យទាំងពីរនេះមានន័យដូចគ្នា។

[2] សំដៅលើវិស័យសាធារណៈ ដែលអាចជារដ្ឋ ភ្នាក់ងាររដ្ឋ ឬនីតិបុគ្គលសាធាណៈ។

**ប្រភពទី២៖**

តាមបណ្ឌិត សាយ បូរី បានបញ្ជាក់ថា សេវាសាធារណៈមានន័យ៣យ៉ាង[3]៖

(១) សេវាសាធារណៈ គឺជាអង្គការ ដែលមានបុគ្គលិក ភ្នាក់ងារធ្វើការ និងមធ្យោបាយសម្រាប់បម្រើប្រយោជន៍សាធារណៈ។ រដ្ឋ និងសមូហភាពរឹមដ្ឋការ អាចបង្កើតសេវាសាធារណៈបានដោយខ្លួនឯង។ នេះគេហៅថាការឲ្យនិយមន័យតាមលក្ខណៈ "អង្គការ" ដែលភាគច្រើនសំដៅទៅលើ "ក្រសួង" ឬ "មន្ទីររបស់ក្រសួង" នៃអង្គការរដ្ឋ និងអង្គការរឹមដ្ឋការ។

(២) សេវាសាធារណៈ គឺជាសកម្មភាពបម្រើផលប្រយោជន៍ទូទៅរបស់រដ្ឋ។ សកម្មភាពនេះ ជួនកាលរដ្ឋកាន់កាប់ដោយខ្លួនឯងផ្ទាល់ (គេហៅថា "រដ្ឋាករ") ជួនកាលរដ្ឋប្រគល់ឲ្យឯកជនកាន់កាប់ ប៉ុន្តែស្ថិតក្រោមការត្រួតពិនិត្យរបស់រដ្ឋ (គេហៅថា "សម្បទានសេវាសាធារណៈ")។ នេះជាការឲ្យនិយមន័យតាមខ្លឹមសារនៃកម្មវត្ថុ។

(៣) សេវាសាធារណៈ គឺជាអត្ថន័យសំខាន់មួយនៃនីតិរដ្ឋបាល ដែលសំដៅទៅលើសកម្មភាពរបស់រដ្ឋនៅក្នុងរបបគតិយុត្តពិសេស ឬរបបគតិយុត្តបដិប្បញ្ញត្តិពីនីតិរួម។ នេះ ជាការឲ្យនិយមន័យតាមលក្ខណៈគតិយុត្ត (ច្បាប់)។

**ប្រភពទី៣៖**

ចំពោះកម្ពុជាវិញ តាមគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ បានកំណត់អំពីនិយមន័យនៃសេវាសាធារណៈ ថា៖ "រាល់សកម្មភាពទាំងឡាយ ដែលធ្វើឡើងដោយ*ស្ថាប័នមានសមត្ថកិច្ច* និង*ស្ថាប័នទទួលសមត្ថកិច្ច* ក្នុងគោលដៅបម្រើផលប្រយោជន៍សាធារណៈ គឺជាសេវាសាធារណៈ"។

"ស្ថាប័នមានសមត្ថកិច្ច" នៅក្នុងន័យនេះ គឺសំដៅដល់ស្ថាប័នរដ្ឋ ឬភ្នាក់ងាររដ្ឋ ឬអាជ្ញាធរគ្រប់លំដាប់ថ្នាក់ទាំងអស់របស់រដ្ឋ ដែលបំពេញការងារតាមដែនសមត្ថកិច្ចរបស់ខ្លួន។

"ស្ថាប័នទទួលសមត្ថកិច្ច" នៅក្នុងន័យនេះ គឺសំដៅដល់ផ្នែកឯកជន និងសង្គមស៊ីវិលដែលទទួលបានសិទ្ធិ និងភារកិច្ចពីរដ្ឋ ហើយដែលស្ថិតនៅក្រោមការគ្រប់គ្រង ត្រួតពិនិត្យរបស់រដ្ឋ ឬភ្នាក់ងាររដ្ឋ។ ការគ្រប់គ្រងការត្រួតពិនិត្យរបស់រដ្ឋ ឬភ្នាក់ងាររដ្ឋទៅលើផ្នែកឯកជន និងសង្គមស៊ីវិលដែលរដ្ឋបានប្រគល់សិទ្ធិអំណាចឲ្យត្រូវធ្វើឡើងផ្អែកលើលក្ខខណ្ឌដូចមានចែងក្នុងសេចក្តីសម្រេច កិច្ចព្រមព្រៀង ឬកិច្ចសន្យាដែលបានប្រគល់ភារកិច្ចក្នុងវង្វង់ដែនសមត្ថកិច្ចមួយច្បាស់លាស់ និងពិនិត្យទៅលើសកម្មភាពការងារ លទ្ធផលដែលសម្រេចបាន គោលដៅទៅអនាគត និងផលប៉ះពាល់ផ្សេងៗជាយថាហេតុ ដែលអាចកើតមានចំពោះសង្គមជាតិ។

**ខ. ចរិតលក្ខណៈនៃសេវាសាធារណៈ**

តាមនិយមន័យខាងលើបង្ហាញឲ្យឃើញថា មានចរិតលក្ខណៈ ឬចំណុចវិនិច្ឆ័យ ចំនួន៣ ដែលអាចសម្គាល់ ឬកំណត់បានថាសេវាមួយជាសេវាសាធារណៈ។

**(១) សកម្មភាពបម្រើប្រយោជន៍ទូទៅ**[4]៖ សំដៅទៅលើសកម្មភាពទាំងឡាយណាដែលធ្វើឡើងដើម្បីជាប្រយោជន៍ទូទៅ អនុញ្ញាតឲ្យសាធារណៈជនអាចប្រើប្រាស់បានដោយសេរី ដោយស្មើភាព និងដូចៗគ្នា ដោយមិនសម្រាប់តែបម្រើឲ្យផលប្រយោជន៍របស់បុគ្គលណាម្នាក់ ក្រុមណាមួយ ឬផ្នែកណាមួយនៃសង្គម

---

[3] សាយ បូរី, *នីតិរដ្ឋបាលទូទៅ*, ប្អូស្សំ ឡូទឹស បោះពុម្ពលើកទី៣, ភ្នំពេញ, ឆ្នាំ២០០២, ទំព័រទី៤០៣។

[4] ផលប្រយោជន៍ទូទៅ ផលប្រយោជន៍រួម និងផលប្រយោជន៍សាធារណៈ គឺមានន័យដូចគ្នា។

នោះទេ។ ដើម្បីពិនិត្យថា សកម្មភាពមួយបម្រើផលប្រយោជន៍ទូទៅ ឬទេ គឺគេត្រូវមើលលើតម្រូវការនៃសេវានោះទៅតាមពេលវេលា និងទីកន្លែង ព្រមទាំងភាពសមាមាត្ររវាងផលប្រយោជន៍ និងផលប៉ះពាល់របស់វា។

(២) **បំពេញដោយ ឬក្រោមការត្រួតពិនិត្យរបស់បុគ្គលសាធារណៈ៖** សំដៅទៅលើសកម្មភាពដែលបំពេញដោយស្ថាប័នមានសមត្ថកិច្ច ឬស្ថាប័នទទួលសមត្ថកិច្ចក្រោមការត្រួតពិនិត្យរបស់រដ្ឋ ឬភ្នាក់ងាររដ្ឋ (សូមមើលនិយមន័យខាងលើ)។ និយាយឲ្យខ្លី គេត្រូវដឹងថា តើអ្នកណាជាអ្នកបំពេញសេវាសាធារណៈ? ចម្លើយ គឺអ្នកណាក៏បានដែរទោះជារដ្ឋ ឬឯកជនក្តី ឲ្យតែមានការអនុញ្ញាតដោយច្បាប់ ដែលគេហៅថា ស្ថាប័នមានសមត្ថកិច្ច និងស្ថាប័នទទួលសមត្ថកិច្ច។ ករណីឯកជនទទួលសមត្ថកិច្ចផ្តល់សេវាសាធារណៈអ្វីមួយចាំបាច់ត្រូវមានការត្រួតពិនិត្យដោយរដ្ឋ ហើយមានកាតព្វកិច្ចជាប់ចំណងនឹងបុគ្គលសាធារណៈ តាមរយៈកិច្ចសន្យាច្បាស់លាស់ស្តីពីការផ្តល់សេវា ទាំងពេលវេលាផ្តល់សេវា និងតម្លៃប្រើប្រាស់សេវា ។

(៣) **ស្ថិតនៅក្រោមបេបគតិយុត្តពិសេស** ៖ មានន័យថា សកម្មភាពសេវាសាធារណៈ ត្រូវប្រព្រឹត្តទៅក្រោមវិធានគតិយុត្តពិសេស ដាច់ដោយឡែកពីវិធានរួម ឬនីតិឯកជន ។ វិធាននេះ សំដៅលើនីតិរដ្ឋបាល ឬនីតិសាធារណៈសម្រាប់គ្រប់គ្រងរដ្ឋ ស្ថាប័ន និងសកម្មភាពសាធារណៈ។ ប៉ុន្តែមិនមានន័យថា គ្រប់សកម្មភាពសេវាសាធារណៈស្ថិតនៅក្រោមតែវិធានគតិយុត្តពិសេសមួយប៉ុណ្ណោះនោះទេព្រោះសេវាសាធារណៈមួយចំនួនមិនត្រឹមតែអនុលោមតាមវិធានគតិយុត្តពិសេសប៉ុណ្ណោះទេ ប៉ុន្តែបានប្រើប្រាស់វិធាននៃនីតិរួមសម្រាប់ការរៀបចំ និងការប្រព្រឹត្តទៅរបស់ខ្លួន ជាពិសេសសេវាសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច។

ដូចនេះ សេវាទាំងឡាយណាដែលបំពេញបាននូវលក្ខខណ្ឌទាំង៣ខាងលើ ទើបហៅថា "សេវា-សាធារណៈ" ។ មានន័យថា *"សេវាសាធារណៈ គឺជាសកម្មភាពទាំងឡាយណាដែលធ្វើឡើងក្នុងគោលដៅបម្រើផលប្រយោជន៍ទូទៅ ទោះសកម្មភាពនោះបំពេញដោយរដ្ឋ ភ្នាក់ងាររដ្ឋ អាជ្ញាធរ ឬបុគ្គលសាធារណៈ ឬបំពេញដោយឯកជន ឬអង្គការសង្គមស៊ីវិលក្តី ប៉ុន្តែត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់រដ្ឋ ឬភ្នាក់ងាររដ្ឋ និងត្រូវអនុវត្តតាមវិធានគតិយុត្តពិសេស ឬនីតិសាធារណៈ"*។

**គ. ការចាត់ថ្នាក់សេវាសាធារណៈ**

គេអាចធ្វើចំណាត់ថ្នាក់សេវាសាធារណៈតាម ២របៀប គឺ របៀបទី១៖ គេចែកជាសេវាសាធារណៈរដ្ឋបាល និងសេវាសាធារណៈសេដ្ឋកិច្ច និងរបៀបទី២៖ គេចែកជាសេវាសាធារណៈថ្នាក់ជាតិ និងសេវាសាធារណៈមូលដ្ឋាន។

*របៀបទី១៖ សេវាសាធារណៈរដ្ឋបាល និងសេវាសាធារណៈសេដ្ឋកិច្ច*

| | **សេវាសាធារណៈរដ្ឋបាល** | **សេវាសាធារណៈសេដ្ឋកិច្ច** |
|---|---|---|
| កម្មវត្ថុនៃសេវា | មិនស្វែងរកប្រាក់ចំណេញ | ស្វែងរកប្រាក់ចំណេញ |
| ធនធានសម្រាប់ដំណើរការសេវា | ធនធាន មធ្យោបាយ បុគ្គលិក និងហិរញ្ញវត្ថុរបស់រដ្ឋ | ធនធាន មធ្យោបាយ បុគ្គលិក និងហិរញ្ញវត្ថុរបស់ឯកជន |
| បែបបទនៃការរៀបចំសេវា | រចនាសម្ព័ន្ធគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅ ធ្វើឡើងតាមបែបផែនរបស់រដ្ឋ | រចនាសម្ព័ន្ធគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅ ធ្វើឡើងតាមបែបផែនរបស់ក្រុមហ៊ុនឯកជន |

*របៀបទី២៖ សេវាសាធារណៈថ្នាក់ជាតិ និងសេវាសាធារណៈមូលដ្ឋាន*

សេវាសាធារណៈថ្នាក់ជាតិ ជាទូទៅសំដៅទៅលើសេវាទាំងឡាយណាដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ព្រោះជាសេវាតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋ និងសង្គមជាតិ។ សេវាទាំងនោះ មានដូចជា សេវាការពារជាតិ សេវាអប់រំ សេវាសុខាភិបាល សេវាយុត្តិធម៌ ។ល។ ជាក់ស្តែង រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ បានកំណត់ពីសេវាសាធារណៈថ្នាក់ជាតិ នៅក្នុងជំពូកទី៣ និយាយអំពីសិទ្ធិ និងករណីកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ ជំពូកទី៥ និយាយអំពីសេដ្ឋកិច្ច និងជំពូកទី៦ និយាយអំពីអប់រំ វប្បធម៌ និងសង្គមកិច្ច។

សេវាសាធារណៈមូលដ្ឋាន ជាទូទៅសំដៅទៅលើសេវាទាំងឡាយណាដែលមានចែងក្នុងច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាក់ស្តែងសម្រាប់កម្ពុជា សេវាប្រភេទនេះ មានកំណត់នៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដូចជា សេវា មធ្យោបាយ សម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈជាមូលដ្ឋាន ការអភិវឌ្ឍមូលដ្ឋាន អនាម័យ ផាសុកភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ ការធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ។ល។

បើតាមគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈរបស់កម្ពុជា សេវាសាធារណៈ ត្រូវបានបែងចែកជា ៧ចង្កោមធំៗ នោះគឺ ចង្កោមសេវាពាក់ព័ន្ធនឹងអធិបតេយ្យភាពរដ្ឋ ចង្កោមសេវាពាក់ព័ន្ធនឹងផ្នែកសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ចង្កោមសេវាពាក់ព័ន្ធនឹងយុត្តិធម៌ និងអាជ្ញាកណ្តាល ចង្កោមសេវាពាក់ព័ន្ធនឹងការលើកកម្ពស់កិច្ចការពាណិជ្ជកម្ម សហគ្រាសធុនតូច និងមធ្យម បរិស្ថានវិនិយោគ និងការចូលរួមផ្នែកឯកជនក្នុងការកសាង និងការថែទាំហេដ្ឋារចនាសម្ព័ន្ធ ចង្កោមសេវាសង្គមកិច្ច វប្បធម៌ និងកិច្ចការនារី ចង្កោមសេវាពាក់ព័ន្ធនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងចង្កោមសេវាពាក់ព័ន្ធនឹងការប្រមូលចំណូល ការធ្វើវិចារណកម្មចំណាយ និងការបើកផ្តល់។

## ២. របបគតិយុត្ត

### ក. ការបង្កើត

**(១) សេវាសាធារណៈថ្នាក់ជាតិ៖** ចាំបាច់ត្រូវតែបង្កើតឡើងដោយរដ្ឋធម្មនុញ្ញ និងច្បាប់ ពីព្រោះពេលបង្កើតសេវាសាធារណៈ គឺត្រូវចំណាយថវិកា ដែលថវិកាទាំងអស់នេះ បានពីការប្រមូលពន្ធពីប្រជា-ពលរដ្ឋ។ ដូចនេះ ក្នុងការបង្កើតសេវាសាធារណៈដែលត្រូវចាយថវិការដ្ឋ គឺត្រូវតែមានការពេញចិត្តពីប្រជា-ពលរដ្ឋ តាមរយៈរដ្ឋសភា មានន័យថា មានតែស្ថាប័ននីតិប្បញ្ញត្តិទេ ដែលមានសិទ្ធិបង្កើតសេវាសាធារណៈ។ ដូចនេះ សេវាសាធារណៈ (ក្រៅពីសេវាដែលមានកំណត់ក្នុងរដ្ឋធម្មនុញ្ញ) ចាំបាច់ត្រូវបង្កើតដោយច្បាប់។

**(២) សេវាសាធារណៈមូលដ្ឋាន៖** សំដៅទៅលើសេវានៅថ្នាក់ក្រោមជាតិមិនមែនសេវាសាធារណៈជាមូលដ្ឋានទេ។ សេវាសាធារណៈជាមូលដ្ឋាន គឺសំដៅទៅលើផ្លូវ ស្ពាន ការអប់រំ សុខាភិបាល អគ្គិសនី ទឹកភ្លើង ។ល។ ប៉ុន្តែនៅទីនេះ គឺសិក្សាពីសេវាសាធារណៈមូលដ្ឋាន ដែលមានលក្ខណៈ៣យ៉ាងដូចខាងក្រោម៖

- *កាតព្វកិច្ចបង្កើត៖* សំដៅទៅលើសេវាដែលរដ្ឋ (ពិសេសអាជ្ញាធរមូលដ្ឋាន) ចាំបាច់ត្រូវតែផ្តល់ជូនប្រជាពលរដ្ឋ។ តាមច្បាប់នៅកម្ពុជា ពុំមានបញ្ជាក់ពីសេវាសាធារណៈមូលដ្ឋានដែលរដ្ឋបាលថ្នាក់ក្រោមជាតិមានកាតព្វកិច្ចត្រូវតែបង្កើត និងផ្តល់ជូនប្រជាពលរដ្ឋឲ្យបានច្បាស់លាស់ទេ ក្រៅពីសេវារក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ ការជំរុញកិច្ចអភិវឌ្ឍន៍

សេដ្ឋកិច្ច សង្គមកិច្ច និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាដើម គឺសុទ្ធតែមានលក្ខណៈមិនច្បាស់លាស់ ព្រោះមានភាពទូលំទូលាយពេក។ បើពិនិត្យទៅលើសេវាសាធារណៈមូលដ្ឋាននៅអឺរ៉ុប គឺគេមានកំណត់ជាក់លាក់ ដូចជា ឃុំ/សង្កាត់មានភារកិច្ចរៀបចំឲ្យមានសេវាសាធារណៈប្រមូលសំរាម ទីកន្លែងចាក់សំរាម រៀបចំឲ្យមានទីស្ងប់សុខ (ទីកប់ខ្មោច) មណ្ឌលកុមារ និងទារក។ រដ្ឋបាលថ្នាក់ស្រុក មានភារកិច្ចបង្កើត រៀបចំ និងគ្រប់គ្រងសាលាបឋមសិក្សា រដ្ឋបាលថ្នាក់ខេត្ត/តំបន់ មានភារកិច្ចបង្កើត រៀបចំ និងគ្រប់គ្រងអនុវិទ្យាល័យ និងវិទ្យាល័យ រីឯរដ្ឋបាលថ្នាក់ជាតិ (ក្រសួងអប់រំ) មានភារកិច្ចបង្កើត រៀបចំ និងគ្រប់គ្រងឧត្តមសិក្សា។

- *សេវាដែលច្បាប់ហាមបង្កើត៖* សំដៅទៅលើសេវាដែលច្បាប់ហាមឃាត់មិនឲ្យអាជ្ញាធរមូលដ្ឋានបង្កើត ឬចាត់ចែងជាដាច់ខាត។ ករណីនេះច្បាប់នៅកម្ពុជាបានកំណត់ច្បាស់លាស់ ដូចជា សេវាទាក់ទងនឹងវិស័យការពារជាតិ វិស័យការទូត វិស័យព្រៃឈើ វិស័យរូបិយវត្ថុ។ ការប្រព្រឹត្តផ្ទុយពីបញ្ញត្តិទាំងនេះ គឺជាការខុសច្បាប់។
- *សេវាដែលអាចបង្កើតដោយសេរី៖* សំដៅទៅលើប្រភេទសេវាដែលច្បាប់អនុញ្ញាតឲ្យអាជ្ញាធរមូលដ្ឋាន បង្កើត ចាត់ចែង និងផ្តល់ជូនប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់ខ្លួន។ ច្បាប់នៅកម្ពុជាបើកទូលាយឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ បង្កើតសេវាសាធារណៈនៅមូលដ្ឋានរបស់ខ្លួនដោយសេរី បន្ថែមពីលើសេវាកាតព្វកិច្ចដែលរដ្ឋតម្រូវឲ្យបង្កើត និងក្រៅពីសេវាដែលច្បាប់បានហាមឃាត់ដូចបានបញ្ជាក់ខាងលើ។ ការបង្កើតសេវាសាធារណៈមូលដ្ឋានប្រភេទនេះ ត្រូវសម្រេចដោយដីការបស់ក្រុមប្រឹក្សរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។

ខ. **ការផ្តល់សេវាសាធារណៈ៖** មធ្យោបាយជាសកលដែលគេបានប្រើក្នុងការផ្តល់សេវាសាធារណៈមាន៣ ដូចខាងក្រោម៖

**(១) ការផ្តល់ដោយបុគ្គលសាធារណៈផ្ទាល់៖** ជាការផ្តល់សេវាសាធារណៈដោយប្រើប្រាស់បុគ្គលិក ធនធាន មធ្យោបាយ និងថវិការបស់រដ្ឋ។ ការផ្តល់បែបនេះ ហៅថា "រដ្ឋាករ" ភាគច្រើនគេតែងអនុវត្តចំពោះសេវាអធិបតេយ្យភាពរបស់រដ្ឋ។

**(២) ប្រតិភូកម្មឲ្យបុគ្គលសាធារណៈ៖** រដ្ឋបានផ្តល់សមត្ថកិច្ចទៅឲ្យគ្រឹះស្ថានជំនាញជាអ្នកផ្តល់សេវាជំនួស ដែលគេអាចហៅបានថា ជាការធ្វើវិមជ្ឈការបច្ចេកទេស។ បុគ្គលសាធារណៈនៅទីនេះ សំដៅទៅលើគ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ[5]។

**(៣) ការធ្វើប្រតិភូកម្មឲ្យបុគ្គលឯកជន៖** សេវាសាធារណៈទាំងឡាយណាក្រៅពីសេវាអធិបតេយ្យភាពរបស់រដ្ឋ គឺអាចធ្វើប្រតិភូកម្មឲ្យឯកជនបាន។ ប៉ុន្តែសេវាអធិបតេយ្យ អាចមិនដូចគ្នាពីប្រទេសមួយទៅប្រទេសមួយទៀត ហើយវាមានលក្ខណៈតិចទៅៗសម្រាប់ប្រទេសអភិវឌ្ឍន៍។ ការធ្វើប្រតិភូកម្មឲ្យបុគ្គលឯកជន ចាំបាច់ត្រូវមាន វិធាន និងទម្រង់នៃប្រតិភូកម្មច្បាស់លាស់ តាមរូបភាពជាសម្បទានសេវាសាធារណៈ[6]

---

[5] មើលព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧.៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល និង ព្រះរាជក្រមលេខ ជស/រកម/០៦៩៦.០៣ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩៦ ប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ។

[6] ច្បាប់ស្តីពីសម្បទាន (នស.រកម.១០០៧.០២៧ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧)

ប្រវាស់សេវាសាធារណៈ ឬអាចរហូតដល់ការធ្វើឯកជនភាវូបនីយកម្ម (ដូចជា ករណីនៃការធ្វើឯកជនភាវូបនីយកម្មលើវិស័យអប់រំ)។

ចំពោះកម្ពុជា បាន និងកំពុងអនុវត្តយន្តការចំនួន៩ ក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។ យន្តការទាំង៩នេះ រួមមាន៖ (១) ការកែលម្អកិច្ចដំណើរការការងារនៃការផ្តល់សេវា (២) យន្តការច្រកចេញចូលតែមួយ (៣) វិសហមជ្ឈការសេវាសាធារណៈ (៤) វិមជ្ឈការសេវាសាធារណៈ (៥) គ្រឹះស្ថានសាធារណៈរដ្ឋបាល (៦) សហគ្រាសសាធារណៈ (៧) កិច្ចសន្យា (៨) ភ្នាក់ងារប្រតិបត្តិការពិសេស និង (៩) ឯកជនភាវូបនីយកម្ម។

**គ. "ច្បាប់" របស់សេវាសាធារណៈ៖** សំដៅដល់គោលការណ៍របស់សេវាសាធារណៈគ្រប់ប្រភេទ ទាំងសេវាដែលបង្កើតដោយរដ្ឋធម្មនុញ្ញ និងដោយច្បាប់។ សេវាសាធារណៈទាំងនេះ ត្រូវមានគោលការណ៍៣ ដូចខាងក្រោម៖

**(១) និរន្តរភាព៖** គ្រប់សេវាសាធារណៈទាំងអស់ ត្រូវផ្តល់ឲ្យដោយជាប់ជានិច្ច (Continue) និងទៀតពេលវេលា (punctual)។ គោលការណ៍និរន្តរភាពនេះ មានលក្ខខណ្ឌតឹងរឹងបំផុត (១០០%) សម្រាប់សេវាមួយចំនួនដូចជា សេវាការពារជាតិ សេវាការពារសណ្តាប់ធ្នាប់សាធារណៈ សេវាសុខាភិបាល (ពេទ្យ) គឺសុទ្ធតែមិនអាចខកខានបាន។

**(២) សមភាព៖** អ្នកប្រើប្រាស់សេវាសាធារណៈទាំងអស់ត្រូវទទួលសិទ្ធិ និងកាតព្វកិច្ចស្មើៗគ្នា ចំពោះមុខសេវាសាធារណៈ។ អ្នកផ្តល់សេវាសាធារណៈ ត្រូវផ្តល់ដោយស្មើភាព អព្យាក្រឹត្យ យុត្តិធម៌ មិនរើសអើងចំពោះជាតិសាសន៍ ឬបុគ្គលណាមួយឡើយ "ហៅថាសិទ្ធិទទួលបានសេវាសម្រាប់អ្នកប្រើប្រាស់" ហើយអ្នកទទួលសេវាអាចបង់ថ្លៃសេវាតាមការកំណត់របស់ច្បាប់ "ហៅថាកាតព្វកិច្ចចំពោះមុខសេវា"។ ប៉ុន្តែ គោលការណ៍នេះមានអញ្ញត្រកម្ម ព្រោះសមភាពខ្លះអាចបណ្តាលឲ្យមានវិសមភាព ឧទាហរណ៍ ការកំណត់ថ្លៃឆ្លងទូកដ ដូចគ្នារវាងអ្នកឆ្លងកាត់ជាប្រចាំ (សិស្ស និងគ្រូបង្រៀនដែលឆ្លងទូកទៅរៀន និងបង្រៀននៅត្រើយម្ខាងទៀត) និងអ្នកឆ្លងកាត់ម្តងមួយកាល។ ដូចនេះ ទើបមានអញ្ញត្រកម្មក្នុងការកំណត់ឲ្យមានវិសមភាពតាមនីត្យានុកូល "វិសមភាពបែបនេះ គឺជាការរើសអើងដោយវិជ្ជមាន"។ ជាក់ស្តែង ការកំណត់តម្លៃផ្សេងគ្នាសម្រាប់អ្នកឆ្លងទូកដរាល់ថ្ងៃ និងអ្នកឆ្លងម្តងមួយកាល ការកំណត់តម្លៃចូលទស្សនាផ្សេងគ្នារវាងជនបរទេស និងជនជាតិខ្មែរ ។ល។

**(៣) បរិវត្តភាព៖** សំដៅទៅលើការវិវត្ត ការសម្របសម្រួលឲ្យត្រូវទៅនឹងបរិបទជាក់ស្តែង។ មានន័យថា សេវាសាធារណៈត្រូវតែវិវត្តទៅតាមស្ថានភាពជាក់ស្តែង។ ដូចនេះ សេវាសាធារណៈ អាចត្រូវបានប្តូរ ឬលុបចោលតែម្តង ជាក់ស្តែងកម្មវិធីសិក្សា សេវាទូកដ (ប៉ះពាល់ដល់ជីវិតអ្នករត់ទូកដ) ជាដើម។

**៣. សន្និដ្ឋាន**

តាមការបង្ហាញខាងលើ យើងអាចកំណត់និយមន័យ និងចរិតលក្ខណៈនៃសេវាសាធារណៈថា *ជាសកម្មភាពទាំងឡាយណាដែលធ្វើឡើងក្នុងគោលដៅ**បម្រើផលប្រយោជន៍ទូទៅ** ទោះសកម្មភាពនោះ បំពេញដោយរដ្ឋ ភ្នាក់ងាររដ្ឋ អាជ្ញាធរ ឬបុគ្គលសាធារណៈ ឬបំពេញដោយឯកជន ឬអង្គការសង្គមស៊ីវិលក្តី ប៉ុន្តែត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់រដ្ឋ ឬភ្នាក់ងាររដ្ឋ និងត្រូវអនុវត្តតាមវិធានគតិយុត្តបដិប្បញ្ញត្តិពី*

*នីតិរូប* ។ សេវាសាធារណៈអាចត្រូវបានបែងចែកជាសេវាសាធារណៈថ្នាក់ជាតិ និងសេវាសាធារណៈមូលដ្ឋាន ឬបែងចែកជាសេវាសាធារណៈរដ្ឋបាល និងសេវាសាធារណៈសេដ្ឋកិច្ច។

សេវាសាធារណៈ ត្រូវបង្កើតឡើងដោយរដ្ឋធម្មនុញ្ញ ច្បាប់ ឬអាចត្រូវបានបង្កើតឡើងដោយដីការបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិសម្រាប់ប្រទេសអភិវឌ្ឍន៍ ឬប្រទេសដែលមានប្រជាធិបតេយ្យរឹងមាំ។ នេះហៅថា របបគតិយុត្តនៃការបង្កើតសេវាសាធារណៈ។ សេវាសាធារណៈ ត្រូវបានផ្តល់ជូនប្រជាពលរដ្ឋតាមរយៈយន្តការចំនួន៣គឺ ការផ្តល់ដោយរដ្ឋផ្ទាល់ ការធ្វើប្រតិភូកម្មឲ្យទៅបុគ្គលសាធារណៈ និងការធ្វើប្រតិភូកម្មឲ្យទៅបុគ្គលឯកជន។ ម្យ៉ាងទៀត គោលការណ៍នៃការផ្តល់សេវាសាធារណៈ ត្រូវមានលក្ខណៈនិរន្តរភាព សមភាព និងបរិវត្តភាព។

ជាគំនិតផ្ទាល់ខ្លួន សេវាសាធារណៈ ជាសេវា ឬសកម្មភាពទាំងឡាយណាដែលប្រជាជននៅក្នុងសង្គមមួយត្រូវការជាចាំបាច់ ហើយសង្គមនោះត្រូវតែបង្កើត និងផ្តល់សេវាទាំងនោះជូនប្រជាជនរបស់ខ្លួន ទោះតាមមធ្យោបាយអ្វីក៏ដោយ (ដោយវិស័យសាធារណៈ ឯកជន ឬអង្គការសង្គមស៊ីវិលក្តី) ឲ្យតែធានាបានថា សេវាទាំងនោះត្រូវបានផ្តល់ជូនប្រជាជនពិតប្រាកដ ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។ មានន័យថា សេវាសាធារណៈមិនសុទ្ធតែដូចគ្នាពីកន្លែងមួយទៅទីកន្លែងមួយ ឬពីប្រទេសមួយទៅប្រទេសមួយទៀតឡើយ ហើយវាអាចនឹងប្រែប្រួលទៅតាមពេលវេលា ដែលជាការវិវត្តនៃតម្រូវការជាក់ស្តែងរបស់មនុស្សនៅតាមទីកន្លែងនីមួយៗ។ តែទោះជាយ៉ាងនេះក្តី គេអាចស្គាល់ពីសេវាដូចគ្នាមួយចំនួនដែលត្រូវបានចាត់ទុកថាជាសេវាសាធារណៈ រួមមាន សេវាអធិបតេយ្យភាព សេវាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ សេវាការពារជាតិ សេវាអប់រំ សេវាសុខាភិបាល សេវាអគ្គីសនី សេវាទឹកស្អាត សេវាកិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ។

**ទី២៖ ការផ្តល់សេវាសាធារណៈដោយវិស័យឯកជន**

ប្រសិនបើវិស័យឯកជនផ្តល់សេវាសាធារណៈ ដោយប្រើមូលនិធិសាធារណៈ តើមានបច្ច័យអ្វីទៅលើវិស័យសាធារណៈ និងកម្រិតប្រសិទ្ធភាពក្នុងម៉ាក្រូសេដ្ឋកិច្ច? (If private sector firms provide public services, funded by public money, what effect does this have on?)

ការផ្តល់សេវាសាធារណៈដោយវិស័យឯកជនដែលទទួលមូលនិធិសាធារណៈ គឺជាផ្នែកមួយនៃឯកជនភាវូបនីយកម្ម ពីព្រោះឯកជនភាវូបនីយកម្មសំដៅទៅលើវិធី និងរបៀបជាច្រើននៃការផ្តល់សមត្ថកិច្ចឲ្យឯកជនដែលរួមមាន ការធ្វើកិច្ចសន្យាក្រៅនៃសេវា ការធ្វើសម្បទានសេវា ការប្រវាស់សេវា ការឧបត្ថម្ភធន ភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន ការផ្តល់សេវារួមគ្នា និងគ្របដណ្តប់រហូតដល់ការលក់ទ្រព្យសកម្មសាធារណៈឲ្យទៅវិស័យឯកជន។ ប៉ុន្តែសម្រាប់*គោលបំណងនៅទីនេះ ពាក្យ "**ឯកជនភាវូបនីយកម្ម**" គឺសំដៅតែទៅលើសកម្មភាព និងការផ្តល់សេវាសាធារណៈដោយវិស័យឯកជនដែលទទួលមូលនិធិសាធារណៈ*។ ចំណែកឯ ពាក្យ "សេវា" ដែលនឹងប្រើជាបន្តបន្ទាប់នេះ គឺផ្តោតតែទៅលើសេវាសាធារណៈប៉ុណ្ណោះ ដោយមិនរាប់បញ្ចូលសេវាឯកជននោះទេ។ ការសិក្សាបញ្ហានៅទីនេះត្រង់ថា៖ ប្រសិនបើសេវាត្រូវបានផ្តល់ដោយឯកជន (ការធ្វើឯកជនភាវូបនីយកម្ម) តើនឹងមានផលប៉ះពាល់យ៉ាងដូចម្តេចទៅលើវិស័យសាធារណៈ? តើការធ្វើឯកជនភាវូបនីយកម្មនេះ នឹងផ្តល់កម្រិតប្រសិទ្ធភាពក្នុងម៉ាក្រូសេដ្ឋកិច្ចយ៉ាងម៉េច? ដូចនេះ រវាងសេវាដែលផ្តល់ដោយវិស័យសាធារណៈ និងវិស័យឯកជន តើមួយណាល្អប្រសើរជាង?

## ១. មូលហេតុនៃការផ្តល់សិទ្ធិឲ្យឯកជនជាអ្នកផ្តល់សេវា

រហូតមកដល់បច្ចុប្បន្ននេះ មានសម្លេងគាំទ្រ និងសម្លេងជំទាស់យ៉ាងច្រើនដើរទន្ទឹមគ្នា ទាក់ទងទៅនឹងការធ្វើឯកជនភាវូបនីយកម្ម។ ប៉ុន្តែ មានទឡ្ហីករណ៍ដែលសំអាងលើបទពិសោធន៍មួយចំនួន បានបង្ហាញ ថាតើសេវាដែលផ្តល់ដោយវិស័យសាធារណៈ ឬឯកជន ដែលមានប្រសិទ្ធភាពជាង? មុននឹងចូលដល់ការវែកញែកពីផលប៉ះពាល់នៃការផ្តល់សេវាដោយឯកជន ទៅលើវិស័យសាធារណៈ ខ្ញុំសូមបង្ហាញនូវការសំអាងមួយចំនួនដែលចាំបាច់តម្រូវឲ្យក្រុមហ៊ុនឯកជនជាអ្នកផ្តល់សេវា (ការធ្វើឯកជនភាវូបនីយកម្មសេវាសាធារណៈ) នោះគឺ៖

(១) បង្កើនភាពទន់ភ្លន់សម្រាប់ប្រសិទ្ធភាពនៃការផ្តល់សេវា ដែលជាលទ្ធផលទទួលបានពីការកាត់បន្ថយនូវការិយាធិបតេយ្យ និងនីតិវិធីស្មុគស្មាញនានា។

(២) កាត់បន្ថយចំណាយថ្លៃដើម ដែលជាលទ្ធផលនៃការធ្វើឲ្យប្រសើរឡើងនូវប្រសិទ្ធភាព ពិសេសនៅពេលដែលមានដំណើរការប្រកួតប្រជែងពិតប្រាកដ និងស្មោះត្រង់ ជាមួយនឹងការបង្កើតឲ្យមានលក្ខណៈវិនិច្ឆ័យគុណផល (performance) ច្បាស់លាស់។

លើសពីនេះទៅទៀត មូលហេតុដែលជម្រុញឲ្យវិស័យសាធារណៈសម្រេចចិត្តផ្តល់សិទ្ធិឲ្យឯកជនជាអ្នកផ្តល់សេវាជំនួសខ្លួនបែបនេះ គឺដោយសារ (១) ភាពទោមនស្សរបស់អ្នកប្រើប្រាស់សេវាជាមួយនឹងការបំពេញការងារ ឬសកម្មភាពរបស់វិស័យសាធារណៈ និង(២) ចេតនាក្នុងការផ្តល់សិទ្ធិអំណាចទៅឲ្យអន្តរការីដែលជាអ្នកផ្តល់សេវា (Hatry and Durman 1985)។

## ២. ផលប៉ះពាល់នៅលើវិស័យសាធារណៈ

ជាសត្យានុម័ត រាល់ការសម្រេចចិត្តនីមួយៗតែងមានគុណសម្បត្តិ និងគុណវិបត្តិ ដែលទាមទារឲ្យអ្នកសម្រេចចិត្ត ជាពិសេសអ្នកបង្កើតគោលនយោបាយរបស់រដ្ឋ ត្រូវពិនិត្យ ពិចារណា និងថ្លឹងថ្លែងឲ្យបានគ្រប់ជ្រុងជ្រោយនូវផលប៉ះពាល់ដែលអាចកើតចេញពីសេចក្តីសម្រេចចិត្តនោះ។ ដូចគ្នាដែរ ចំពោះការធ្វើឯកជនភាវូបនីយកម្ម (ឬ ការសម្រេចចិត្តផ្តល់សិទ្ធិឲ្យឯកជនជាអ្នកផ្តល់សេវា) ពិតជាមានផលប៉ះពាល់ទាំងវិជ្ជមាន និងអវិជ្ជមានទៅលើវិស័យសាធារណៈ។

### ក. ផលប៉ះពាល់វិជ្ជមានទៅលើវិស័យសាធារណៈ

គោលដៅចម្បងនៃការធ្វើឯកជនភាវូបនីយកម្ម គឺដើម្បីបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវា ក្នុងការបម្រើប្រជាជន និងសង្គមជាតិឲ្យបានកាន់តែល្អប្រសើរឡើង។ ឯកជនភាវូបនីយកម្ម ជានិន្នាការពិភពលោកពិសេសក្នុងសម័យសកលភាវូបនីយកម្ម ដែលយល់ឃើញថា ក្នុងសេដ្ឋកិច្ចទីផ្សារ រដ្ឋាភិបាលគួរធ្វើសកម្មភាពឲ្យកាន់តែតិច ដោយទុកឲ្យឯកជន ជាអ្នកធ្វើសកម្មភាពឲ្យបានច្រើន ទើបជាការប្រសើរសម្រាប់សេដ្ឋកិច្ចនៅក្នុងប្រទេសនោះ។ ការផ្តល់សិទ្ធិឲ្យឯកជនជាអ្នកផ្តល់សេវាបែបនេះ ជាការបង្កើតឲ្យមានជម្រើសជាច្រើនសម្រាប់អ្នកប្រើប្រាស់សេវា ដែលពួកគាត់អាចជ្រើសរើសអ្នកផ្តល់សេវាណាដែលខ្លួនពេញចិត្ត និងកម្រិតសេវាដែលពួកគាត់ត្រូវការ និងមានលទ្ធភាពប្រើប្រាស់។ ម៉្យាងទៀត សេវាដែលផ្តល់ជូនដោយឯកជន អាចនឹងមានគុណភាពល្អប្រសើរជាងសេវាដែលផ្តល់ជូនដោយវិស័យសាធារណៈ។

ចំពោះវិស័យសាធារណៈ ឯកជនភាវូបនីយកម្ម បានផ្តល់នូវផលជាវិជ្ជមាន មួយចំនួនដូចខាងក្រោម[7]៖

(១) វិស័យសាធារណៈទទួលបាននូវជំនាញពិសេសដែលឯកជនបាននាំមកជាមួយ ដូចជា ការងារគ្រប់គ្រងបែបធុរកិច្ច ការគ្រប់គ្រងទីផ្សារ ឥរិយាបទនៃការផ្តល់សេវា ការធ្វើបដិសណ្ឋារកិច្ច ការប្រើប្រាស់ធនធានឲ្យអស់លទ្ធភាព ។ល។

(២) វិស័យសាធារណៈ ទទួលបាននូវបុគ្គលិកអណ្តែត (ជំនួស) សម្រាប់បំពេញការងារក្នុងរយៈពេលខ្លីទៅតាមគម្រោងនៃការផ្តល់សេវានីមួយៗ ដោយមិនចាំបាច់ជ្រើសរើសបុគ្គលិកដោយខ្លួនឯង និងមិនចាំបាច់ចំណាយថវិកាសម្រាប់ការបណ្តុះបណ្តាល។ មធ្យោបាយនេះ បានជួយយ៉ាងច្រើនសម្រាប់ប្រទេសប្រកាន់យកប្រព័ន្ធអាជីព ពីព្រោះប្រព័ន្ធបែបនេះប្រសិនបើមិនធ្វើឯកជនភាវូបនីយកម្មទេ បុគ្គលិកដែលត្រូវបានជ្រើសរើសនឹងត្រូវរក្សាការងារឲ្យពួកគាត់រហូត ទោះជាការងារនោះត្រូវការពួកគាត់សម្រាប់តែក្នុងរយៈពេលណាមួយក៏ដោយ ក៏រដ្ឋត្រូវតែធានាបន្តការងារជូនពួកគាត់រហូតដល់ចូលនិវត្តន៍ (ករណីគ្មានកំហុសធ្ងន់ធ្ងរណាមួយកើតឡើង)។

(៣) ឯកជនភាវូបនីយកម្ម ជួយកាត់បន្ថយការចំណាយសាធារណៈ ពីព្រោះសេវាទាំងនោះត្រូវបានផ្តល់ឲ្យឯកជនជាអ្នកបំពេញ ដូចនេះ រដ្ឋ ឬវិស័យសាធារណៈមិនចាំបាច់ចំណាយថវិកាសម្រាប់ការបង្កើតអង្គភាព បុគ្គលិក សម្ភារៈការិយាល័យ សម្ភារៈបច្ចេកទេស មធ្យោបាយ អាគារ ទឹកភ្លើង និងធនធានចាំបាច់មួយចំនួនទៀតសម្រាប់បង្កើតសេវា។

(៤) ឯកជនភាវូបនីយកម្ម ជួយសម្រួលការងារដល់វិស័យសាធារណៈឲ្យធូរស្រាល កាត់បន្ថយភាពកកស្ទះ និងការយឺតយ៉ាវមួយចំនួន។

[7] Allen, et al, *The Private Sector in State Service Delivery*, Washington, D.C. The Urban Institute Press, 1989

(៥) វិស័យឯកជន ជួយផ្តល់នូវសេវាដែលអាចឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងសង្គម ដែលនៅផុតពីដៃ ឬលើសពីសមត្ថភាពរបស់រដ្ឋាភិបាល/វិស័យសាធារណៈ។

**ខ. ផលប៉ះពាល់អវិជ្ជមានទៅលើវិស័យសាធារណៈ**

កង្វល់ចម្បងដែលជំទាស់ទៅនឹងការធ្វើឯកជនភាវូបនីយកម្ម (ឬការផ្តល់សិទ្ធិឲ្យវិស័យឯកជនជាអ្នកផ្តល់សេវា) គឺជាប់ទាក់ទងជាសំខាន់ទៅនឹងគុណភាពនៃសេវា និងការប៉ះពាល់ទៅលើការងារនៅក្នុងវិស័យសាធារណៈ។ ក្នុងន័យនេះ ការព្រួយបារម្ភត្រង់ថា វិស័យឯកជនមានគោលដៅក្នុងការស្វែងរកប្រាក់ចំណេញ ដែលអាចជាមូលហេតុធ្វើឲ្យឯកជនកាត់បន្ថយនូវសេវាមួយចំនួន ដែលខ្លួនយល់ថាមិនអាចទទួលបានប្រាក់ចំណេញពីការផ្តល់សេវានោះ ។ ម្យ៉ាងទៀត ការផ្តល់សេវាដោយឯកជន អាចនឹងលម្អៀងទៅរកតែអតិថិជនដែលងាយស្រួលក្នុងការផ្តល់សេវាជូន និងអតិថិជនដែលផ្តល់លទ្ធភាពក្នុងការទទួលបានជោគជ័យសម្រាប់ក្រុមហ៊ុនរបស់ខ្លួនតែប៉ុណ្ណោះ។ ចំណែកឯ កង្វល់អំពីការបាត់បង់ការងាររបស់វិស័យសាធារណៈ គឺកើតចេញពីបុគ្គលិកសាធារណៈ និងសហភាពតំណាងឲ្យបុគ្គលិកសាធារណៈទាំងនោះ។ ជាការពិត ការងារដែលបានបាត់បង់ពីវិស័យសាធារណៈដោយសារការផ្ទេរឲ្យឯកជនជាអ្នកធ្វើ អាចនឹងត្រូវបានទទួលឲ្យបំពេញការងារដោយវិស័យឯកជនដែលជាភាគីកិច្ចសន្យានោះ ឬអាចនឹងត្រូវផ្ទេរឲ្យទៅធ្វើការជាមួយភ្នាក់ងារសាធារណៈផ្សេងៗទៀត។ ប៉ុន្តែ ចំនួនការងារដែលទទួលបានថ្មីនេះ មានចំនួនត្រឹមតែពី ៨០% ទៅ ៩០% ប៉ុណ្ណោះ មានន័យថា ចំនួនពី១០% ទៅ ២០% ទៀត ត្រូវបាត់បង់ការងារជាស្ថាពរតែម្តង[8]។

ខាងក្រោមនេះ[9] ជាផលប៉ះពាល់អវិជ្ជមានទៅលើវិស័យសាធារណៈ ដែលកើតចេញពីការធ្វើឯកជនភាវូបនីយកម្ម (ឬការផ្តល់សិទ្ធិឲ្យក្រុមហ៊ុនឯកជនជាអ្នកផ្តល់សេវា)៖

(១) ធ្វើឲ្យបាត់បង់ការងាររបស់បុគ្គលិកសាធារណៈ

(២) ការធ្វើអនុប្បទាន ឬលះបង់ការទទួលខុសត្រូវរបស់វិស័យសាធារណៈលើមូលនិធិសាធារណៈឲ្យទៅវិស័យឯកជន អាចជាការគំរាមកំហែងដល់គណនេយ្យភាពសារពើពន្ធ ពីព្រោះធុរកិច្ចឯកជនមិនមែនជាការធ្វើអាជីវកម្មដែលជាវិភាជមូលនិធិសាធារណៈឡើយ

(៣) ធ្វើឲ្យទន់ខ្សោយនូវសមត្ថភាពរបស់សហគមន៍ក្នុងការការពារផលប្រយោជន៍សមូហភាព និងធ្វើឲ្យមានការធ្លាក់ចុះនូវការចូលរួមរបស់ប្រជាពលរដ្ឋក្នុងវិស័យសាធារណៈ ក៏ដូចជាក្នុងរដ្ឋាភិបាល

(៤) ផ្តល់លទ្ធភាពខ្ពស់ក្នុងការបំភាន់ ឬធ្វើកិច្ចការអសុចរិត

(៥) មានជម្លោះអត្ថប្រយោជន៍ ទាក់ទងនឹងហិរញ្ញវត្ថុ

(៦) គំរាមកំហែងដល់ការសម្ងាត់នៃព័ត៌មានឯកជន

(៧) បង្កើនការប៉ុនប៉ងក្នុងការកាត់បន្ថយគុណភាពនៃសេវា ដោយសារការកាត់បន្ថយចំណាយថ្លៃដើមក្នុងគោលបំណងបង្កើនប្រាក់ចំណេញឲ្យបានខ្ពស់។

## ៣. ផលប៉ះពាល់ទៅលើកម្រិតប្រសិទ្ធភាពក្នុងម៉ាក្រូសេដ្ឋកិច្ច

ដូចគ្នាដែរ ឯកជនភាវូបនីយកម្ម ក៏នាំមកនូវគុណសម្បត្តិ និងគុណវិបត្តិចំពោះកម្រិតប្រសិទ្ធភាពនៅក្នុងម៉ាក្រូសេដ្ឋកិច្ចផងដែរ។ ដូចនេះ តើឯកជនភាវូបនីយកម្ម ផ្តល់ផលប៉ះពាល់ទៅលើកម្រិតប្រសិទ្ធភាពក្នុងម៉ាក្រូសេដ្ឋកិច្ចយ៉ាងដូចម្តេច?

[8] A report by the National Commission for Employment Policy (1989)
[9] Source: Adapted from materials prepared by the AFL-CIO, Public Employee Department

### ក. ផលប៉ះពាល់វិជ្ជមានទៅលើកម្រិតប្រសិទ្ធភាពក្នុងម៉ាក្រូសេដ្ឋកិច្ច

ការធ្វើឯកជនភាវូបនីយកម្ម ឬការផ្តល់សិទ្ធិឲ្យឯកជនជាអ្នកផ្តល់សេវា គឺជាយន្តការមួយនៃការផ្តល់សេវាសាធារណៈ ដែលបង្កើតឲ្យមាន**ការប្រកួតប្រជែង**នៅក្នុងទីផ្សារ និងជម្រុញឲ្យមានកម្រិតប្រសិទ្ធភាពកាន់ខ្ពស់ក្នុងសេដ្ឋកិច្ចទីផ្សាររបស់ប្រទេស ពីព្រោះការប្រកួតប្រជែង ជាមូលដ្ឋានគ្រឹះនៃភាពជោគជ័យនៅក្នុងប្រវត្តិនៃការធ្វើឯកជនភាវូបនីយកម្មរបស់ប្រទេសប្រកាន់យករបបសេដ្ឋកិច្ចទីផ្សារ។ យ៉ាងណាមិញ ការធ្វើឯកជនភាវូបនីយកម្មនៃសេវាសាធារណៈនេះ ពឹងផ្អែកទាំងស្រុងទៅលើការប្រកួតប្រជែងដោយសុចរិត និងស្មោះត្រង់ ដែលទាមទារឲ្យរដ្ឋមានសមត្ថភាពក្នុងការបង្កើតបទប្បញ្ញត្តិឲ្យបានគ្រប់គ្រាន់ និងពង្រឹងការអនុវត្តរបស់ឯកជនឲ្យបានជិតដល់តាមរយៈការពិនិត្យតាមដាន និងការវាយតម្លៃ ដោយប្រុងប្រយ័ត្នប្រកបដោយការទទួលខុសត្រូវខ្ពស់។ បែបនេះ សេវាសាធារណៈដែលត្រូវបានធ្វើឯកជនភាវូបនីយកម្ម នឹងមានគុណភាពល្អជាង សេវាដែលផ្តល់ដោយរដ្ឋផ្ទាល់ ហើយ **កាត់បន្ថយបាននូវការិយាធិបតេយ្យ និងនីតិវិធីស្មុគស្មាញនានា** ដែលជាមូលដ្ឋានធ្វើឲ្យអតិថិជនមានការពេញចិត្តក្នុងការប្រើប្រាស់សេវាដែលផ្តល់ជូនដោយឯកជន។ ហេតុនេះ សេវាទាំងនោះនឹងមានដំណើរការល្អនៅក្នុងទីផ្សារ ព្រោះទទួលបានការគាំទ្រពីប្រជាពលរដ្ឋ និងអ្នកប្រើប្រាស់ទាំងឡាយ។ មានន័យថា វិស័យឯកជនកាន់តែមានទឹកចិត្តក្នុងការផ្តល់សេវា និងធ្វើឲ្យកាន់តែល្អប្រសើរឡើងនូវសេវារបស់ខ្លួន។ វិស័យឯកជនមានការរីកដុះដាលខ្លាំង នឹងនាំឲ្យមានការប្រកួតប្រជែងទាំងផ្នែកគុណភាព និងតម្លៃ។ ដូចនេះ គេអាចនិយាយបានថា វិស័យឯកជនដែលជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ចរបស់ប្រទេសដែលប្រកាន់យករបបទីផ្សារ នឹងមានឥទ្ធិពលដល់កម្រិតប្រសិទ្ធភាពក្នុងម៉ាក្រូសេដ្ឋកិច្ចទាំងផ្នែក **គុណភាព តម្លៃ និងពេលវេលា** ជាពិសេសកម្រិតផលិតភាពនៃទំនិញ និងសេវា ដែលបង្កើត និងផ្តល់ជូនដោយឯកជន នឹងមានការកើនឡើងកាន់តែខ្ពស់។ ប្រការនេះ ធ្វើឲ្យផលិតផលក្នុងស្រុកសរុប (ផសស) របស់ប្រទេសក៏កាន់តែកើនឡើងខ្ពស់ដែរ។

### ខ. ផលប៉ះពាល់អវិជ្ជមានទៅលើកម្រិតប្រសិទ្ធភាពក្នុងម៉ាក្រូសេដ្ឋកិច្ច

ទន្ទឹមនឹងនេះ ទោះបីជាសេវាដែលផ្តល់ជូនដោយឯកជន ហាក់ដូចជាមានគុណភាពល្អជាងសេវាដែលផ្តល់ជូនដោយវិស័យសាធារណៈក៏ពិតមែន ប៉ុន្តែតម្លៃរបស់វាក៏អាចខ្ពស់ជាងទៅតាមនោះដែរ។ មានន័យថា វាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងគុណភាព និងតម្លៃនៃសេវា។ សំខាន់ជាងនេះទៅទៀត ឯកជនភាវូបនីយកម្ម អាចបង្កើតឲ្យមានអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ដោយសារមូលហេតុនៃការស្វែងរកប្រាក់ចំណេញរបស់វិស័យឯកជន ដែលផ្ទុយពីគោលដៅរបស់វិស័យសាធារណៈ។ អំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ដែលអាចបង្កឲ្យកើតមានដោយឯកជន មានដូចជាៈ

(១) ការបង្កើតឲ្យមានការភ័ន្តច្រឡំតាមមធ្យោបាយណាមួយ ជាមួយសហគ្រាស ជាមួយទំនិញ ឬជាមួយសកម្មភាពឧស្សាហកម្ម ពាណិជ្ជកម្ម ឬសេវាកម្មនៃគូប្រកួតប្រជែង

(២) ការពោលអះអាងមិនត្រឹមត្រូវក្នុងពាណិជ្ជកម្ម ដែលធ្វើឲ្យខូចកេរ្តិ៍ឈ្មោះ សហគ្រាស ទំនិញ ឬសកម្មភាពឧស្សាហកម្ម ពាណិជ្ជកម្ម ឬសេវាកម្មនៃគូប្រកួតប្រជែង

(៣) ការបញ្ជាក់ ឬការពោលអះអាងដែលបានប្រើប្រាស់នៅក្នុងពាណិជ្ជកម្ម ហើយដែលអាចធ្វើឲ្យសាធារណៈជនភ័ន្តច្រឡំ អំពីប្រភេទ ដំណើរការផលិត លក្ខណៈ ភាពសមស្របសម្រាប់គោលបំណងរបស់គេ ឬបរិមាណនៃទំនិញ។

ទង្វើខាងលើនេះ គឺជាផលប៉ះពាល់អវិជ្ជមានទៅលើកម្រិតប្រសិទ្ធភាពក្នុងម៉ាក្រូសេដ្ឋកិច្ចដែលអាចបង្កឡើងដោយអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់របស់វិស័យឯកជន។ លើសពីនេះទៅទៀត ឯកជនភាវូបនីយកម្ម អាចផ្តល់លទ្ធភាពខ្ពស់ក្នុងការបំភាន់ ឬធ្វើកិច្ចការអសុចរិតនានា បង្កឲ្យមានជម្លោះផលប្រយោជន៍ទាក់ទងនឹងហិរញ្ញវត្ថុ គំរាមកំហែងដល់ការសម្ងាត់នៃព័ត៌មានឯកជន និងបង្កើនការប៉ុនប៉ងក្នុងការកាត់បន្ថយគុណភាពនៃសេវា ដោយសារការកាត់បន្ថយចំណាយថ្លៃដើម ក្នុងគោលបំណងនៃបង្កើនប្រាក់ចំណេញឲ្យបានខ្ពស់។

## ៤. សេវាដែលផ្តល់ជូនដោយវិស័យសាធារណៈ និងឯកជន

តើសេវាដែលផ្តល់ជូនដោយវិស័យសាធារណៈ ឬឯកជន ដែលមានប្រសិទ្ធភាពជាង? តាមការពិភាក្សាខាងលើបង្ហាញឲ្យឃើញថា មានហេតុផលរៀងៗខ្លួនទាក់ទងទៅនឹងការគាំទ្រ និងការជំទាស់ចំពោះការធ្វើឯកជនភាវូបនីយកម្ម។ តាមពិត វិស័យនីមួយៗ (ឯកជន និងសាធារណៈ) មានចំណុចខ្លាំង និងខ្សោយរៀងៗខ្លួន ហើយគេក៏មិនអាចនិយាយបានថាការផ្តល់សេវាសាធារណៈដោយឯកជនមានលក្ខណៈល្អប្រសើរ ឬ អាក្រក់ជាងវិស័យសាធារណៈឡើយ។ មានន័យថា "ឯកជនធ្វើរឿងមួយចំនួនបានល្អប្រសើរជាងរដ្ឋ ប៉ុន្តែរដ្ឋធ្វើរឿងមួយចំនួនផ្សេងទៀតបានល្អប្រសើរជាងឯកជន"។ វិស័យសាធារណៈ ធ្វើបានល្អប្រសើរជាងឯកជនសម្រាប់កិច្ចការមួយចំនួន ដូចជា ការគ្រប់គ្រងគោលនយោបាយ ការងារបញ្ញត្តិកម្ម ការធានាសមធម៌ ការទប់ស្កាត់ការជួញដូរខុសច្បាប់ និងការប្រព្រឹត្តបទឧក្រិដ្ឋនានា ការធានានិរន្តរភាព និងស្ថិរភាពនៃសេវា និងការធានាកម្លាំងសាមគ្គីក្នុងសង្គម។ ជាមួយគ្នានេះ ឯកជន ធ្វើបានល្អប្រសើរជាងវិស័យសាធារណៈ ចំពោះកិច្ចការមួយចំនួនផ្សេងទៀត ជាអាទិ៍ កិច្ចការទាក់ទងនឹងសេដ្ឋកិច្ច (ការកសាងហេដ្ឋារចនាសម្ព័ន្ធ ការដឹកជញ្ជូនកំពង់ផែ ...) បច្ចេកវិទ្យា ការចម្លង ឬដកស្រង់បទពិសោធន៍ជោគជ័យនានា ការសម្របតាមការផ្លាស់ប្តូរយ៉ាងលឿនរហ័សនៃមជ្ឈដ្ឋានជុំវិញ ក៏ដូចជាការប្រែប្រួលនៃនិន្នាការរបស់ពិភពលោក ។ល។

ដូចនេះ គេមិនអាចនិយាយបានភ្លាមថា ការផ្តល់សេវាដោយឯកជនមានប្រសិទ្ធភាពខ្ពស់ ឬទាបជាងវិស័យសាធារណៈនោះទេ ព្រោះវាអាស្រ័យទៅតាមប្រភេទនៃសេវាដែលផ្សារភ្ជាប់ជាមួយនឹងចំណុចខ្លាំង និងចំណុចខ្សោយរបស់វិស័យនីមួយៗ។ ជាពិសេស ភាពជោគជ័យនៃការផ្តល់សេវា គឺ ផ្តោតជាសំខាន់ទៅលើការអនុវត្ត ដែលទាមទារឲ្យមានការគ្រប់គ្រង ការពិនិត្យ តាមដាន និងការវាយតម្លៃឲ្យបានត្រឹមត្រូវ និងច្បាស់លាស់។

## ៥. សន្និដ្ឋាន

ផ្អែកលើការបកស្រាយខាងលើ បង្ហាញឲ្យឃើញថា ឯកជនភាវូបនីយកម្មអាចធ្វើប៉ះពាល់ដល់ការងារនៅនៅក្នុងវិស័យសាធារណៈ ធ្វើឲ្យទន់ខ្សោយនៃសមត្ថភាពរបស់សហគមន៍ក្នុងការការពារផលប្រយោជន៍សមូហភាព កាត់បន្ថយការចូលរួមរបស់ប្រជាជននៅក្នុងវិស័យសាធារណៈ កាត់បន្ថយគណនេយ្យភាពសារពើពន្ធ ប្រឈមនឹងការបាត់បង់និរន្តរភាពនៃសេវា និងគុណភាពនៃសេវាអាចធ្លាក់ចុះដោយសារឯកជនចង់ទទួលបានប្រាក់ចំណេញខ្ពស់ហើយត្រូវកាត់បន្ថយចំណាយលើថ្លៃដើម។ ជាមួយគ្នានេះ ឯកជនភាវូបនីយកម្មផ្តល់ផលវិជ្ជមានជាច្រើន ដល់សេដ្ឋកិច្ចសង្គម ដូចជា ការជំរុញឲ្យមានការប្រកួតប្រជែង ការកាត់បន្ថយបាននូវការិយាធិបតេយ្យ និងនីតិវិធីស្មុគស្មាញនានា ការទទួលបាននូវសេវាដែលមានគុណភាពខ្ពស់ និងតម្លៃសមរម្យដែលអាចទទួលយកបានទៅតាមការប្រកួតប្រជែងក្នុងទីផ្សារ ព្រមទាំងពេលវេលានៃការទទួលបានសេវាលឿន

ហ៊ែស។ លក្ខណៈបែបនេះ គឺទទួលបាននូវការពេញចិត្ត និងការគាំទ្រដាខ្លាំងពីអ្នកប្រើប្រាស់សេវា ដែលជាការជម្រុញលើកទឹកចិត្តឲ្យវិស័យឯកជនកាន់តែរីកដុះដាល និងធ្វើឲ្យកម្រិតប្រសិទ្ធភាពនៅក្នុងម៉ាក្រូសេដ្ឋកិច្ចរបស់ប្រទេសកាន់តែល្អប្រសើរឡើង។

ដូចនេះ ផ្អែកលើការស្រាវជ្រាវដែលប្រៀបធៀបប្រសិទ្ធភាពនៃសេវាដែលផ្តល់ដោយវិស័យសាធារណៈ និងឯកជន គេអាចសន្និដ្ឋានបានថា៖

(១) គ្មានទឡ្ហីករណ៍បែបពិសោធន៍ណាមួយបង្ហាញថា សេវាដែលផ្តល់ដោយភាគីកិច្ចសន្យាឯកជន មិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការផ្តល់សេវាឲ្យបានល្អប្រសើរពេញលេញនោះទេ

(២) មានទឡ្ហីករណ៍ដែលទាញចេញពីការសិក្សាស្រាវជ្រាវមួយចំនួន បានបង្ហាញថា គុណភាពនៃសេវានៅក្នុងប្រព័ន្ធផ្តល់សេវាឯកជនមានលក្ខណៈល្អប្រសើរជាងប្រព័ន្ធសាធារណៈ ប៉ុន្តែវាមានទំនាក់ទំនងយ៉ាងជិតស្និទជាមួយនឹងប្រសិទ្ធភាពនៃថ្លៃចំណាយ។ ទោះជាយ៉ាងណា លទ្ធផលជាច្រើនបានបង្ហាញថា អ្នកប្រើប្រាស់សេវាមានការពេញចិត្តលម្អៀងទៅខាងវិស័យឯកជនច្រើនជាង

(៣) នៅពេលដែលសេវាសាធារណៈត្រូវបានផ្តល់ឲ្យឯកជន នោះនឹងមានការកាត់បន្ថយចំនួនបុគ្គលិកសាធារណៈ ប៉ុន្តែមិនមានការកាត់បន្ថយការងារ ឬចំនួនបុគ្គលិកទាំងអស់នោះទេ

(៤) តាមបទពិសោធន៍កន្លងមក គេឃើញមានទាំងភាពជោគជ័យ ទាំងបរាជ័យ នៅក្នុងវិស័យទាំងពីរ (ឯកជន និងសាធារណៈ) មានន័យថា គ្មានគំរូណាមួយដែលល្អប្រសើរ ឬមានប្រសិទ្ធភាពជាងគំរូណាមួយឡើយ គឺវាអាស្រ័យទៅលើការអនុវត្តដែលត្រូវផ្សារភ្ជាប់ជាមួយនឹងគណនេយ្យភាពនៃលទ្ធផល លក្ខណៈវិនិច្ឆ័យនៃគុណផល និងគោលបំណងសាធារណៈ ច្បាស់លាស់។

ជារួម ឯកជនភាវូបនីយកម្ម ឬការផ្តល់សិទ្ធិឲ្យក្រុមហ៊ុនឯកជនជាអ្នកផ្តល់សេវា នាំមកនូវគុណសម្បត្តិនៃការប្រកួតប្រជែង និងភាពទន់ភ្លន់ក្នុងការផ្តល់សេវាសាធារណៈ ដែលធ្វើឲ្យប្រសិទ្ធភាពនៃការផ្តល់សេវាកាន់តែខ្ពស់ កាន់តែឆ្លើយតបទៅនឹងតម្រូវការរបស់អតិថិជន និងលើកទឹកចិត្តឲ្យមានការបង្កើតថ្មី។ ផ្ទុយទៅវិញ សម្រាប់វិស័យសាធារណៈ ប្រហែលជាពិបាកនឹងសម្រេចបានក្នុងការបំពេញការងារជាគុណសម្បត្តិខាងលើឲ្យដូចជាវិស័យឯកជន ដោយសារការដាក់កម្រិតនៃការជួលបុគ្គលិកសាធារណៈ និងបញ្ហាថវិកាដែលទាក់ទងទៅនឹងការចំណាយ។ ទន្ទឹមនឹងនេះ ឯកជនភាវូបនីយកម្ម ក៏ជួបបញ្ហាខាងហានីភ័យផងដែរ និងទាមទារឲ្យមានការគ្រប់គ្រងដោយប្រុងប្រយ័ត្នពីភ្នាក់ងារសាធារណៈ។ បញ្ហាត្រង់ថា កិច្ចសន្យានៃការផ្តល់សិទ្ធិឲ្យឯកជនខ្វះការឆ្លុះបញ្ចាំងពីគណនេយ្យភាព និងលក្ខណៈវិនិច្ឆ័យនៃគុណផល ហើយប្រសិទ្ធភាពនៃកិច្ចសន្យា គឺអាស្រ័យទៅលើការអនុវត្តកិច្ចសន្យាដែលតម្រូវឲ្យមានការពិនិត្យតាមដានជាបន្តបន្ទាប់។ ដូចនេះ ដើម្បីសម្រេចឲ្យបាននូវអត្ថប្រយោជន៍ប្រកបដោយសក្តានុពលនៃឯកជនភាវូបនីយកម្ម ភ្នាក់ងារសាធារណៈត្រូវកំណត់តួនាទីរបស់ភាគីកិច្ចសន្យាឲ្យបានជាក់លាក់ កំណត់ថ្លៃឲ្យបានត្រឹមត្រូវ និងបង្កើតលក្ខណៈវិនិច្ឆ័យគុណផលឲ្យបានច្បាស់លាស់។ លើសពីនេះ ភ្នាក់ងារសាធារណៈត្រូវពិចារណាទៅលើសមត្ថភាពរយៈពេលវែងរបស់ខ្លួន ដើម្បីរៀបចំឲ្យមានរចនាសម្ព័ន្ធ និងពិនិត្យតាមដានគំនិតផ្តួចផ្តើមនៃការធ្វើឯកជនភាវូបនីយកម្មក្នុងគោលដៅធានាប្រសិទ្ធភាពនៃតម្លៃ និងគុណភាពនៃការផ្តល់សេវាដែលប្រើប្រាស់មូលនិធិសាធារណៈ។